**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៥៧១០ សហវ.ទប

ថ្ងៃ ចន្ទ ៣ រោច ខែ ភទ្របទ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៩

## ជម្រាបជូន

## ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**__កម្មវត្ថុ:__** ករណីសំណើសុំគោលការណ៍ធានាចំណាយជំពូក៦៥ ចំនួន ៧ ០៥៥ ០០០ ០០០រៀល សម្រាប់បើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែគ្រូបង្រៀន និងថវិកាដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ។

**__យោង:__** លិខិតលេខ ២១៧៩ អយក.ហវ ចុះថ្ងៃទី០៣-០៥-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដើម្បីឱ្យការអនុវត្តចំណាយថវិកាសម្រាប់ការរៀននិងបង្រៀននៅតាមមត្តេយ្យសហគមន៍ដែលមានលក្ខណៈស្តង់ដា ប្រព្រឹត្តទៅដោយរលូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងឯកភាពជាគោលការណ៍ដូចតទៅ ÷

១- សម្រាប់ប្រាក់ឧបត្ថម្ភជូនគ្រូបង្រៀនមត្តេយ្យសហគមន៍ដែលមានលក្ខណៈស្តង់ដា - អនុញ្ញាតឱ្យអនុវត្តនីតិវិធីទូទាត់ត្រង់ ដោយក្រសួងអប់រំ យុវជន និងកីឡា ត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជារៀងរាល់ខែ និងបង្វែរចូលគណនីនៅធនាគាររបស់សាមីខ្លួន ។ ការអនុវត្តនេះត្រូវស្របតាមសារាចរណែនាំលេខ០១១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត ។

ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានការពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងក្នុងក្របខ័ណ្ឌនៃបុគ្គលិកជាប់កិច្ចសន្យាជារួម ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

២- សម្រាប់ចំណាយដំណើរការមត្តេយ្យសហគមន៍ដែលមានលក្ខណៈស្តង់ដា - អនុញ្ញាតឱ្យផ្តល់ថវិកាសម្រាប់ដំណើរការមត្តេយ្យសហគមន៍ដែលមានលក្ខណៈស្តង់ដា ជូនលោកគ្រូ អ្នកគ្រូ ដើម្បីរៀបចំដំណើរការ និងទិញសម្ភារៈឧបទេស និងសម្ភារៈបង្រៀន ក្នុងអំឡុងពេលដែលក្រសួងអប់រំ យុវជន និងកីឡាបណ្តុះបណ្តាលជូនលោកគ្រូ អ្នកគ្រូមត្តេយ្យដែលមានលក្ខណៈស្តង់ដា នៅដើមឆ្នាំ ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវតាមដាននូវការអនុវត្តចំណាយថវិកាដំណើរមត្តេយ្យសហគមន៍ដែលមានលក្ខណៈស្តង់ដាឱ្យបានហ្មត់ចត់ ដើម្បីធានាប្រសិទ្ធភាព និងតម្លាភាព ។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន ÷</u>**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកសារ-កាលប្បវត្តិ